ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

លេខ : ៤៣៩៤ ផប

# សេចក្តីណែនាំ
## ស្តីពី
## លក្ខខណ្ឌតម្រូវបច្ចេកទេសសម្រាប់ទីតាំងប្រមូលផ្តុំសត្វជ្រូក

នាបច្ចុប្បន្ននេះដើម្បីបំពេញតម្រូវការសត្វជ្រូកសម្រាប់ផ្គត់ផ្គង់ទីផ្សារនៅរាជធានីភ្នំពេញ និងទីផ្សារតាមបណ្តាខេត្តមួយចំនួន តម្រូវឲ្យមានការនាំចូលជ្រូកសាច់ពីបរទេសបន្ថែម ។ ក្នុងគោលបំណងទប់ស្កាត់ការឆ្លងរាលដាលជំងឺសត្វ រក្សាបាននូវនិរន្តរភាពនៃផលិតកម្មសត្វនិងការពារសុខភាពសត្វក្នុងព្រះរាជាណាចក្រកម្ពុជា នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលសូមធ្វើការណែនាំដល់បណ្តាក្រុមហ៊ុនដែលបានដាក់ពាក្យស្នើសុំនាំចូលជ្រូកសាច់ពីបរទេសទាំងអស់ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវបច្ចេកទេសសម្រាប់ទីតាំងប្រមូលផ្តុំសត្វជ្រូកដូចខាងក្រោម៖

១-ចំពោះទីតាំងប្រមូលផ្តុំសត្វជ្រូកនៅចំណុចដើមទីត្រូវស្ថិតនៅតាមច្រកព្រំដែនដែលបានព្រមព្រៀងគ្នារវាងប្រទេសទាំង២

ក- ច្រកដែលបានព្រមព្រៀងគ្នារវាងកម្ពុជា-ថៃ រួមមាន:

| ល.រ | កម្ពុជា | | | ថៃឡង់ | | |
|---|---|---|---|---|---|---|
| | ខេត្ត | ស្រុក | ឈ្មោះច្រក | ខេត្ត | ស្រុក | ឈ្មោះច្រក |
| ១ | ឧត្តមានជ័យ | អន្លង់វែង | ជាំ | Sisaket | Phousing | Sagnam |
| ២ | បន្ទាយមានជ័យ | ថ្មពួក | បឹងត្រកួន | Sakaew | Tapraya | Tapraya |
| ៣ | បន្ទាយមានជ័យ | ប៉ោយប៉ែត | ប៉ោយប៉ែត | Sakaew | Aranyaprathet | Klongleuk |
| ៤ | បន្ទាយមានជ័យ | អូរជ្រៅ | អូរបីជាន់ | Sakaew | Nonemakmoun | Kok Soung |
| ៥ | បន្ទាយមានជ័យ | ម៉ាឡៃ | ម៉ាឡៃ | Sakaew | Aranyaprathet | Sabprik |
| ៦ | បាត់ដំបង | សំពៅលូន | ភ្នំដី | Sakaew | Klongleuk | Khoa Din |
| ៧ | បាត់ដំបង | ភ្នំព្រឹក | ភ្នំព្រឹក (អូររំដួល) | Sakaew | Aranyaprathet | Ban Nongpreu |
| ៨ | បាត់ដំបង | កំរៀង | ដូង | Chantaburi | Poungnamron | Ban Lam |
| ៩ | បាត់ដំបង | កំរៀង | អូរអន្លក់ | Chantaburi | Soi Dao | Suan Som |
| ១០ | ប៉ៃលិន | សាលាក្រៅ | ព្រំ | Chantaburi | Poungnamron | Ban Prakket |
| ១១ | កោះកុង | មណ្ឌលសីមា | ចាំយាម | Trat | Klong Yai | Had Lek |

ខ- ច្រកដែលបានព្រមព្រៀងគ្នារវាងកម្ពុជា-វៀតណាម រួមមាន:

| ល.រ | កម្ពុជា | | វៀតណាម | |
|---|---|---|---|---|
| | ខេត្ត | ឈ្មោះច្រក | ខេត្ត | ឈ្មោះច្រក |
| ១ | តាកែវ | ភ្នំដិន | An Giang | Tinh Bien |
| ២ | កណ្តាល | ជ្រៃធំ | An Giang | Khanh Binh |
| ៣ | ព្រៃវែង | បន្ទាយចក្រី | Dong Thap | Dinh Ba |
| ៤ | ព្រៃវែង | កោះរកា | Dong Thap | Thuong Puoc |
| ៥ | កំពង់ចាម | ត្រពាំងផ្លុង | Tay Ninh | Xamat |
| ៦ | ស្វាយរៀង | បាវិត | Tay Ninh | Moc Bai |
| ៧ | ស្វាយរៀង | សំរោង | Long An | Thomo |
| ៨ | ស្វាយរៀង | ព្រៃវល្លិ | Long An | Binh Hiep |
| ៩ | ក្រចេះ | ត្រពាំងស្រែ | Binh Phuoc | Hoa Lu |
| ១០ | កំពត | ព្រែកចាក | Kien Giang | Ha Tien |
| ១១ | កំពត | ទាន់ហាន់ | Kien Giang | Giang Thanh |
| ១២ | មណ្ឌលគីរី | ដាក់ដាំ | Daknong | Bu Prang |

២- ត្រូវស្ថិតនៅលើទីតាំងមួយសមស្រប មិនលិចទឹក ដែលមានចំងាយពីសាលារៀន មន្ទីរពេទ្យ វត្តអារាម ទីប្រជុំជនដទៃទៀត បឹង ស្ទឹង ទន្លេ ប្រភពទឹកនានា ដែលមនុស្សនិងសត្វប្រើប្រាស់ជាប្រក្រតី យ៉ាងតិច៥០០ម៉ែត្រចំពោះទីតាំងប្រមូលផ្តុំសត្វជ្រូកចំណុចដើមទីនិងចំងាយយ៉ាងតិច២០០ម៉ែត្រ ចំពោះទីតាំងប្រមូលផ្តុំសត្វជ្រូកចំណុចចុងទី

៣- ត្រូវមានប្រព័ន្ធគមនាគមន៍ងាយស្រួលក្នុងការបម្រើសកម្មភាពដឹកជញ្ជូនសត្វជ្រូកចូលនិងចេញ

៤- ត្រូវមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធអគ្គិសនីសម្រាប់ប្រើប្រាស់គ្រប់គ្រាន់និងតាមលក្ខណៈ បច្ចេកទេស

៥- ត្រូវមានរបងព័ទ្ធជុំវិញបរិវេណកន្លែងប្រមូលផ្តុំសត្វជ្រូកកំពស់យ៉ាងតិច១.៥ ម៉ែត្រនិងត្រូវមានប្រព័ន្ធលូ បង្ហូរទឹកកខ្វក់ កាកសំណល់និងអាងស្តុកធ្វើប្រព្រឹត្តិកម្ម

៦- ត្រូវមានបន្ទប់រដ្ឋបាលនិងបន្ទប់ប្រចាំការសម្រាប់មន្ត្រីបសុពេទ្យមានសមត្ថកិច្ច

៧- ត្រូវមានបន្ទប់រដ្ឋបាល បន្ទប់សម្រាកសម្រាប់បុគ្គលិក

៨- ត្រូវមានបន្ទប់សម្រាប់កម្មករស្នាក់នៅ

៩- ត្រូវមានបន្ទប់ទឹកនិងបង្គន់អនាម័យ

១០- កន្លែងស្តុកជ្រូកៈ អាគាររៀបគដ្ឋ ឬកស៊ីម៉ង់ត៍ឬដែកព័ទ្ធសំណាញ់ឬរបាដែក ប្រក់ដំបូល ចាក់សាបផ្ទៃខាងក្រោមមានទំហំ១.៥ម៉ែត្រការ៉េចំពោះជ្រូកមួយក្បាលនិងមានឧបករណ៍សម្រាប់ផ្តល់ទឹកនិងចំណី

១១- កន្លែងសម្រាប់ធ្វើជីវសុវត្ថិភាពៈ ច្រកចេញ-ចូលនៃទីតាំងប្រមូលផ្តុំសត្វជ្រូក ត្រូវមានប្រពន្ធ័សំលាប់មេរោគ រួមមានៈ អាងទឹកថ្នាំសំលាប់មេរោគដែលជារណ្តៅនៅលើច្រកចេញ-ចូលសំរាប់មធ្យោបាយដឹកជញ្ជូនឆ្លងកាត់និងការបាញ់ថ្នាំសំលាប់មេរោគ លើមធ្យោបាយដឹកជញ្ជូន ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រុមហ៊ុនដែលបានដាក់ពាក្យស្នើសុំគោលការណ៍នាំចូលជ្រូកសាច់ពីបរទេសត្រូវបំពេញតាមការណែនាំនេះឲ្យបានជាមុនសិន [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ២០១១

**ប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល**

កៅ ផល

<u>កន្លែងទទួល</u> :

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-មន្ទីរកសិកម្មរាជធានី ខេត្ត
-ក្រុមហ៊ុនទាំង ១៣
-ឯកសារ-កាលប្បវត្តិ